# ប្រកាស
## ស្តីពីការកែសម្រួលប្រកាសស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេស

## ទេសាភិបាល  ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៩0៤/២៤៤ ចុះថ្ងៃទី 0៧ ខែកញ្ញា ឆ្នាំ ២00៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា  ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧-00-0៥ ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២000 ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី 0៤ ខែកញ្ញា ឆ្នាំ ២00៦

## ស ំ រេ ច

**ប្រការមួយ.-**

កែសម្រួលប្រការ ៩ និងប្រការ ១៣ នៃប្រកាសលេខធ៧-00-0៥ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២000 ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ មានដូចខាងក្រោម ៖

**ប្រការ៩ថ្មី.-**

ធនាគារជាតិនៃកម្ពុជា  ផ្តល់អាជ្ញាប័ណ្ណមិនមានកំណត់រយៈពេលសុពលភាពចំពោះធនាគារឯកទេសដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ១៣ថ្មី.៉**

ធនាគារឯកទេស ដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុន ស្មើនឹងប្រាំភាគរយ(៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ដោយទទួលបានកំរៃការប្រាក់ដូចខាងក្រោម ÷

ក.ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកំរៃការប្រាក់ប្រចាំឆ្នាំស្មើនឹងមួយភាគពីរ (១/២) នៃអត្រាការប្រាក់បុនហិរញ្ញប្បទាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយដែលអាចទូទាត់ក្នុងរយៈពេល៦ខែម្តង ។

ខ.ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកំរៃការប្រាក់បីភាគប្រាំបី (៣/៨) នៃអត្រា SIBOR (Singapore Inter-Bank Offered Rate) ក្នុងរយៈពេល៦ខែម្តង។ ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងទៅធនាគារទាំងអស់ ពីអត្រាការប្រាក់ ដែលបានអនុវត្តសំរាប់កាលកំណត់និមួយៗ ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះ នៅពេលធនាគារឯកទេសនោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្ត និងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

**ប្រការពីរ.៉**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការបី.៉**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៦

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការពីរ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"